# L & I PUBLICATIONS:

# របៀបបង្កើតអាជីវកម្មក្នុងទីក្រុង PHILADELPHIA

L & I PUBLICATIONS:
How To Start Business In The City of Philadelphia

GLOBAL PHILADELPHIA

Licenses & Inspection (ផ្នែកអាជ្ញាប័ណ្ណនិងអធិការកិច្ច): យើងនិយាយភាសារបស់អ្នក

Publication Number: 141-A

Revision Date: 11/05

## ការចេញអាជ្ញាប័ណ្ណ

## តើ THE DEPARTMENT OF LICENSES & INSPECTIONS (ក្រសួងអាជ្ញាប័ណ្ណ និងអធិការកិច្ច) មានតួនាទីអ្វី?

The Department of Licenses and Inspections (L & I) (ក្រសួង អាជ្ញាប័ណ្ណ និងអធិការកិច្ច) គឺជាភ្នាក់ងារនិយតកម្មសំខាន់ជាងគេបំផុតសំរាប់ទីក្រុង Philadelphia ។ ការទទួលខុសត្រូវសំខាន់មួយ ក្នុងចំណោមការទទួលខុសត្រូវសំខាន់ជាច្រើនរបស់ក្រសួងនេះ គឺដើម្បីដាក់កំរិតច្បាប់លើអាជីវកម្មទាំងឡាយ តាមរយៈការចេញ អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតអាជីវកម្ម។ The License Issuance Unit (អង្គភាពចេញអាជ្ញាប័ណ្ណ) ពិនិត្យ និងបញ្ជូនសំណើរស្នើរសុំអាជ្ញាប័ណ្ណនានា និងចេញឯកសារដែលចាំបាច់សំរាប់អនុវត្តសកម្មភាពផ្សេងៗ។

## ធ្វើយ៉ាងដូចម្តេចទៅ ទើបខ្ញុំដឹងថាខ្ញុំត្រូវការអាជ្ញាប័ណ្ណមួយសំរាប់ប្រភេទអាជីវកម្មរបស់ខ្ញុំ?

License Issuance (ការចេញអាជ្ញាប័ណ្ណ)នឹងជួយអ្នកអោយទទួលបាននូវព័ត៌មានអំពីដំណើរការនេះ ក៏ដូចជាផ្តល់នូវកញ្ចប់សំណុំបែបបទពាក្យសុំ នៅពេលមានការស្នើសុំ។

សំរាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅលេខទូរស័ព្ទពិសេសរបស់ License Issuance (ការចេញអាជ្ញាប័ណ្ណ)

**686-2490**

នៅពេលអ្នកនិយាយទៅកាន់អ្នកតំណាងផ្នែកសេវាកម្ម សូមរៀបចំ និងផ្តល់ព័ត៌មានដូចខាងក្រោម :

- ឈ្មោះរបស់អ្នកដាក់ពាក្យសុំ និងអាសយដ្ឋាន
- អាសយដ្ឋានអាជីវកម្ម
- ការពិពណ៌នាពីអាជីវកម្ម

អ្នកតំណាងផ្នែកសេវាកម្ម នឹងផ្តល់ព័ត៌មានស្តីពី :

- ប្រភេទនៃអាជ្ញាប័ណ្ណ (មួយ ឬច្រើន) ដែលអាជីវកម្មនោះត្រូវការ

- ថ្លៃចំណាយលើអាជ្ញាប័ណ្ណនីមួយៗ
- តើអ្នកអាចបំពេញល័ក្ខខ័ណ្ឌផ្សេងទៀត ដើម្បីទទួលបានអាជ្ញាប័ណ្ណទាំងនេះដែរឬទេ?

  ( ឧទាហរណ៏ ការឯកភាពការបែងចែកតំបន់អាជីវកម្ម លិខិតបញ្ជាក់កាន់កាប់ ការឯកភាពរបស់ Health Department ( ក្រសួងសុខភាព) ។ល ។ )

អ្នកតំណាងនឹងផ្ញើអោយអ្នកនូវកញ្ចប់ពាក្យសុំ ទៅតាមសំណើរបស់អ្នក ។ អ្នកទទួលបានឯកសារនេះដោយផ្ទាល់តាមរយៈ ឬដោយផ្ញើលិខិតផ្ញើសុំទៅកាន់ :

Department of Licenses and Inspections ( ក្រសួងអាជ្ញាប័ណ្ណ និងអធិការកិច្ច)
1401 John F. Kennedy Boulevard
Public Services Concourse
Philadelphia, PA 19102

<u>សំគាល់</u> : ប្រសិនបើលោកអ្នកមិនបានទូរស័ព្ទមកក្នុងកំឡុងពេលម៉ោងធ្វើការធម្មតានោះទេ លោកអ្នកនឹងទទួលសេវាកម្មឆ្លើយតបមួយ ។ សូមធ្វើការផ្តាំផ្ញើ បន្ទាប់មកអ្នកតំណាងម្នាក់នឹងទូរស័ព្ទត្រឡប់មកវិញ ឬផ្ញើឱ្យលោកអ្នកនូវកញ្ចប់មួយ ទៅតាមសំណើររបស់លោកអ្នក ។

## តើនៅក្នុងកញ្ចប់ពាក្យសុំមានអ្វីខ្លះ ?

កញ្ចប់ដែលអ្នកទទួលបាន មាន :

- ពាក្យសុំសំរាប់លេខពន្ធអាជីវកម្មទីក្រុង Philadelphia
- ពាកសុំសំរាប់ប្រភេទអាជ្ញាប័ណ្ណនីមួយៗ ដែលលោកអ្នកចង់ទទួលបាន
- សេចក្តីណែនាំស្តីពីរបៀបបំពេញបែបបទ

<u>សំគាល់</u> : សូមអានក្រដាសណែនាំដោយប្រុងប្រយ័ត្ន មុនពេលចាប់ផ្តើមបំពេញ

## តើមានជំហានអ្វីខ្លះក្នុងការបំពេញកញ្ចប់ពាក្យសុំ?

នៅពេលលោកអ្នកទទួលបានកញ្ចប់នេះ និងបានអានក្រដាសណែនាំ សូមធ្វើតាមជំហានដូចខាងក្រោម :

**ជំហានទីមួយ** → <u>ទទួលបានការឯកភាពទាំងអស់ ដែលជាល័ក្ខខ័ណ្ឌ ដើម្បីទទួលបានអាជ្ញាប័ណ្ណ ( មួយ ឬច្រើន ដែលចង់បាន )</u>

អាចមានការឯកភាពជាច្រើន ដែលចាំបាច់ដើម្បីផ្តល់អាជ្ញាប័ណ្ណដល់អាជីវកម្មរបស់អ្នក ។ ការឯកភាពខ្លះក្នុងចំណោមការឯកភាពទាំងនេះ ត្រូវបានផ្តល់ឱ្យតាមរយៈ L & I ។ ការឯកភាពត្រូវបានមកពី City departments ( ក្រសួងទីក្រុង) ។ ខាងក្រោមនេះគឺជាបញ្ជីឈ្មោះ Department ( ក្រសួង) រួមជាមួយប្រភេទឯកភាពទូទៅមួយចំនួន :

1. **ការឯកភាព L & I**

ក្រសួងនេះ ដាក់កំរិតច្បាប់លើការប្រើប្រាស់ដីធ្លី និងសំណង់ ។ អ្នកអាចចាំបាច់ត្រូវការការឯកភាពទាំងនេះ ។

- ការឯកភាពលើការបែងចែកតំបន់អាជីវកម្ម

គ្មានអាជីវកម្មណាមួយអាចទទួលបានអាជ្ញាប័ណ្ណនោះទេ លើកលែងតែទីតាំងអាជីវកម្មត្រូវបានបែងចែកជាតំបន់យ៉ាងត្រឹមត្រូវ ។

License Issuance ( ការចេញអាជ្ញាប័ណ្ណ) នឹងធ្វើឱ្យអ្នកដឹងថាតើអ្នកត្រូវដាក់ពាក្យទៅ Zoning Unit ( អង្គភាពបែងចែកជាតំបន់) ដើម្បីទទួលបានការឯកភាពដែរឬយ៉ាងណានោះ ។ ក្នុងករណីជាច្រើន ប្រសិនបើប្រភេទអាជីវកម្ម ដែលអ្នកមានបំណងចង់បើក គឺដូចគ្នាទៅនឹងអាជីវកម្មមួយ ដែលធ្លាប់បើកដំណើរការនៅអាសយដ្ឋានដដែល នោះមិនចាំបាច់មានការឯកភាពលើតំបន់បន្ថែមទៀតនោះទេ ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំអាជីវកម្មប្រភេទផ្សេងទៀតនៅត្រង់ទីតាំងដដែលនោះវិញ អ្នកត្រូវចាំបាច់មានការឯកភាពនេះក្នុងករណីភាគច្រើន ។

ក្នុងកំឡុងពេលដំណើរការពិនិត្យឡើងវិញលើការបែងចែកតំបន់ គេធ្វើការប្រៀបធៀបរវាង " ការចុះបញ្ជីប្រើប្រាស់ " ដែលថ្មីៗនេះកំពុងមានលើសំណុំឯកសារ និងការដាក់ស្នើប្រើប្រាស់របស់អ្នក ។ ប្រសិនបើសំណង់នោះត្រូវបានប្រើប្រាស់ខុសពីការប្រើប្រាស់របស់ម្ចាស់កាលពីមុន នោះអ្នកចាំបាច់ត្រូវមានលិខិតអនុញ្ញាតចុះបញ្ជីប្រើប្រាស់មួយ ។ លិខិតអនុញ្ញាតនេះគឺជាឯកសារកត់ត្រាជាផ្លូវការរបស់ក្រុងស្តីពីការប្រើប្រាស់ថ្មីនៃទីតាំងអាជីវកម្ម ។

អ្នកអាចស្នើសុំពាក្យសុំបែងចែកតំបន់អាជីវកម្ម ដោយទូរស័ព្ទមកកាន់ *Zoning Unit* តាមរយៈលេខ **686-2435** ។

- <u>លិខិតអនុញ្ញាតសាងសង់ (អាគារ/បំពង់ទឹក/អគ្គិសនី)</u>

ប្រសិនបើសំណង់របស់អ្នកគឺជាសំណង់ថ្មី ឬប្រសិនបើសំណង់មានស្រាប់ត្រូវការនូវការជួសជុលកែលំអ ជាទ្រង់ទ្រាយធំសំរាប់ដំណើរការអាជីវកម្មដែលបានដាក់ស្នើ នោះត្រូវមានការឯកភាពពីអង្គភាពចេញលិខិតអនុញ្ញាតដែលសមស្រប សំរាប់ការងារស្ថាបនា ។

សំរាប់ព័ត៌មានស្តីពី ..... លិខិតអនុញ្ញាតស្ថាបនា សូមទូរស័ព្ទមកលេខ **686-2467**

លិខិតអនុញ្ញាតតបណ្តាញទឹកសូមទូរស័ព្ទមកលេខ **686-2578**

លិខិតអនុញ្ញាតតបណ្តាញអគ្គិសនី សូមទូរស័ព្ទមកលេខ **686-2513**

- <u>លិខិតបញ្ជាក់ការកាន់កាប់</u>

អាជ្ញាប័ណ្ណអាជីវកម្មខ្លះតំរូវឱ្យលោកអ្នកមានលិខិតឯកភាពលើការកាន់កាប់ មុនពេលលោកអ្នកអាចទទួលបានអាជ្ញាប័ណ្ណមួយ ។ ករណីនេះជាធម្មតាកើតឡើងក្នុងកាលៈទេសៈ នៅពេលដែលអាគារនោះគឺជាអាគារថ្មី ឬនៅពេលណាដែលការប្រើប្រាស់មានការប្រែប្រួល ។ លិខិតបញ្ជាក់ស្តីពីការកាន់កាប់ (C.O.) បញ្ជាក់ថា ល័ក្ខខ័ណ្ឌតំរូវចាំបាច់របស់អាគារនោះ ត្រូវបានបំពេញហើយ ។

ដំណើរការទទួលបាន C.O. មួយ ចាប់ផ្តើមមានឡើងនៅក្នុងផ្នែកសេវាកម្មអាគាររបស់ L & I នៅពេលអ្នកដាក់ពាក្យសុំលិខិតអនុញ្ញាតមួយ ។ ជាចុងក្រោយ ការិយាល័យខ័ណ្ឌរបស់យើងជាអ្នកចេញ C. O. ជាក់ស្តែង បន្ទាប់ពីការងារដែលបានបញ្ចប់ជាស្ថាពរ ត្រូវបានត្រួតពិនិត្យហើយនោះ ។ នៅពេលលោកអ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណអាជីវកម្មរបស់ខ្លួន លោកអ្នកប្រហែលជាត្រូវដាក់ច្បាប់ចម្លងមួយនៃ C.O. ទៅ License Issuance (ការចេញអាជ្ញាប័ណ្ណ) រួមជាមួយនឹងពាក្យសុំអាជ្ញាប័ណ្ណរបស់លោកអ្នក ។ ការណ៏នេះនឹងអនុញ្ញាតឱ្យអង្គភាពអាចដំណើរការពិនិត្យលើពាក្យសុំនោះកាន់តែរហ័សជាងមុន ។ សូមលោកអ្នកកុំផ្ញើឯកសារច្បាប់ដើមឱ្យសោះ ។

សំរាប់ព័ត៌មាបន្ថែមស្តីពី C.O. សូមទូរស័ព្ទមកសេវាកម្មសាងសង់ តាមលេខ **686-2467**

- ការចុះត្រួតពិនិត្យដល់ទីតាំង <u>– Business Compliance Unit</u> (អង្គភាពអនុលោមអាជីវកម្ម)

អាជ្ញាប័ណ្ណជាក់លាក់មួយចំនួនដូចជាចំណតរថយន្ត និងយានដ្ឋាន ទីធ្លាកាកសំណល់យានយន្ត និងកន្លែងបោកគក់ តំរូវឱ្យមានការចុះត្រួតពិនិត្យដល់ទីកន្លែង ដែលជាផ្នែកមួយនៃនីតិវិធីផ្តល់អាជ្ញាប័ណ្ណ ។ ការចុះត្រួតពិនិត្យនេះ ត្រូវបានជំរុញដោយពាក្យសុំនេះផ្ទាល់ និងត្រូវបញ្ចប់ជាស្ថាពរ មុនពេលអាជ្ញាប័ណ្ណត្រូវបានបោះចេញ

។ ពាក្យសុំរបស់លោកអ្នកនឹងត្រូវបញ្ជូនទៅដោយស្វ័យប្រវត្តិទៅកាន់ *L & I Business Compliance Unit* ( អង្គភាពអនុលោមតាមអាជីវកម្ម L & I ) ដើម្បីធ្វើការត្រួតពិនិត្យ ។

- ការចុះត្រួតពិនិត្យដល់ទីកន្លែង – Commercial and Industrial Fire Inspection Unit ( អង្គភាពត្រួតពិនិត្យអគ្គីភ័យឧស្សាហកម្ម និងពាណិជ្ជកម្ម)

The *Commercial and Industrial Fire Inspection Unit* (C & I) ធ្វើការចុះត្រួតពិនិត្យដល់ទីកន្លែង ដើម្បីរកមើលកត្តាសុវត្ថិភាព ក្នុងទីកន្លែងប្រជុំគ្នាជាសាធារណៈ ។ ប្រសិនបើលោកអ្នកដំណើរការអាជីវកម្មមួយដូចជាសាលរាំ ឬស្ទូឌីយោរាំ ពាក្យសុំអាជ្ញាប័ណ្ណរបស់លោកអ្នកនឹងត្រូវបញ្ជូនទៅ C & I ដើម្បីទទួលបានការឯកភាព ។

- ផែនការអគ្គីភ័យ – Fire Plans Inspection Unit ( អង្គភាពត្រួតពិនិត្យផែនការអគ្គីភ័យ)

អាជីវកម្មដែលប្រើប្រាស់សារធាតុគ្រោះថ្នាក់ ដូចជាឧស្ម័នបំណ្ពុល ឬអាសេទីឡែនចាំបាច់ត្រូវមានលិខិតឯកភាពនេះ ។ ផែនការ ( ឧទាហរណ៍ រូបគំនូសបប្លង់) ប្រហែលជាត្រូវគេតំរូវឱ្យមាន ។

សំរាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទមក *Fire Unit* តាមរយៈលេខ **686-2534**

2. ការឯកភាពរបស់ក្រសួងសុខាភិបាល **(Health Department)**

អាជីវកម្មដែលទាក់ទងនឹងអាហារ ក៏ដូចជាសហគ្រាសផ្សេងៗទៀត ដូចជាហាងកាត់សក់ និងហាងកែ សម្ផស្សចាំបាច់ត្រូវមានការឯកភាពពីក្រសួងសុខាភិបាល ។ ក្រដាសណែនាំដែលដាក់ភ្ជាប់ជាមួយនឹងពាក្យសុំអាជ្ញាប័ណ្ណរបស់លោកអ្នក នឹងផ្តល់ព័ត៌មានដល់លោកអ្នកថាតើចាំបាច់ត្រូវមានការឯកភាពនេះនៅពេលណា ។

សំរាប់ព័ត៌មានបន្ថែម សូមធ្វើការទាក់ទងមកមជ្ឈមណ្ឌលសុខាភិបាលណាមួយក្នុងចំណោមមជ្ឈមណ្ឌលសុខាភិបាលខាងក្រោមនេះ ។

| ខ័ណ្ឌ | អាស័យដ្ឋាន និងលេខទូរស័ព្ទ | |
|---|---|---|
| Center City and South Phila. (#1,2,& 6) | 500 S. Broad St., Zip 19146 | (685-6572) |
| West and Southwest Phila. (#3 & 4) | 555 S. 43rd St., Zip 19104 | (685-2285) |
| North and N.W. Phila. (#5,8,& 9) | 131 E. Chelten Ave., Zip 19144 | (685-2285) |

| | |
|---|---|
| Northeast Phila. (#7 & 10) | 2230 Cottman Ave., Zip 19149 (685-0620) |
| Vendors | 321 University Ave., Zip 19104 (685-7495) |

3. ការឯកភាពរបស់ **Police Department** ( ក្រសួងប៉ូលីស )

បណ្ដាសកម្មភាពដែលទទួលបានអាជ្ញាប័ណ្ណជាក់លាក់ ត្រូវបានតាមដានត្រួតពិនិត្យដោយ Police Department ។ សកម្មភាពទាំងនេះរួមមានដូចជាការលក់អាវុធ និងគ្រាប់រំសេវ ឬការបើកដំណើរការបន្ទប់ អាងហែលទឹក ឬសាលរាំ ។ ក្រដាសណែនាំដែលដាក់ភ្ជាប់ជាមួយនឹង ពាក្យសុំអាជ្ញាប័ណ្ណរបស់លោកអ្នក នឹងផ្ដល់ព័ត៌មានដល់លោកអ្នកថាតើចាំបាច់ត្រូវមានការឯកភាពនេះនៅពេលណា ។

L & I នឹងបញ្ជូនពាក្យសុំរបស់អ្នកទៅប៉ូលីស ដើម្បីទទួលបានការឯកភាព ក្នុងករណីចាំបាច់ ។

សំរាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទមក *Police Department* ( ក្រសួងប៉ូលីស) តាមលេខ **686-3656**.

4. ការឯកភាពរបស់ **Streets Department** ( ក្រសួងផ្លូវថ្នល់)

អាជ្ញាប័ណ្ណសំរាប់អាជីវកម្មដែលពាក់ព័ន្ធនឹងចិញ្ចើមថ្នល់ និងផ្លូវថ្នល់ ដូចជាស្តង់លក់កាសែត ឬចំណតយានយន្តចាំបាច់ត្រូវមានការឯកភាពពី Streets Department ( ក្រសួងផ្លូវថ្នល់) ។ គេអាចតំរូវឱ្យមានការគូសគំនូសប្លង់ដោយការដាក់កំរិតលេខច្បាស់លាស់ ) ។ សូមអានពាក្យសុំអាជ្ញាប័ណ្ណអាជីវកម្មរបស់លោកអ្នកដោយប្រុងប្រយ័ត្ន ។ លេខទូរស័ព្ទដែលទាក់ទងនឹងអង្គភាពសមស្របនេះ នឹងចុះក្នុងបញ្ជីនៅលើពាក្យសុំនោះ ។

សំរាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទមក *Streets Department* តាមរយៈលេខ **686-5501**

5. **Art Commission** ( គណៈកម្មាការសិល្បៈ)

រូបសញ្ញា រនាំងបាំងសាច ឆ័ត្រធំ ឬរបស់តាំងភ្ជាប់ ឬគ្រោងសំណង់ស្រដៀងគ្នានេះផ្សេងទៀត ដែលរំលោភលើ ចិញ្ចើមផ្លូវសាធារណៈ ឬមានទីតាំងស្ថិតនៅក្នុងតំបន់ Zoning Control Area ( តំបន់ត្រួតពិនិត្យការបែងចែកតំបន់ជាក់លាក់ ) អាចចាំបាច់ត្រូវមានការឯកភាពរបស់ Art Commission ( គណៈកម្មការសិល្បៈ) ។ លោកអ្នកប្រហែលជាត្រូវគេតំរូវឱ្យដាក់ស្នើរូបគំនូសប្លង់ការងារនៃការរចនាជាក់ស្តែង ( គូសក្រិត្យតាមមាត្រដ្ឋាន) និងឯកសារផ្សេងៗទៀត ។

គណៈកម្មាការសិល្បៈមានទីតាំងស្ថិតនៅ 12th Floor of 1515 Arch Street. សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទលេខ **683-2095** ។

**ជំហានទី ២**

<u>បំពេញពាក្យសុំសំរាប់លេខគណនីពន្ធអាជីវកម្មក្រុង Philadelphia</u>

(ប្រសិនបើអ្នកមានលេខគណនីពន្ធអាជីវកម្មក្រុង Philadelphia ហើយ សូមរំលងជំហានទី ២ នេះ)

ពាក្យសុំសំរាប់ល័ក្ខខ័ណ្ឌតំរូវចាំបាច់នេះ នឹងត្រូវបានដាក់បញ្ចូលជាមួយកញ្ចប់របស់អ្នក។ សូមចងចាំថាត្រូវចុះហត្ថលេខាលើពាក្យសុំនេះ នៅពេលណាអ្នកបានបំពេញចូលនូវព័ត៌មានដែលចាំបាច់ ។ នៅពេលលោកអ្នកទទួលបានលេខគណនីពន្ធអាជីវកម្មមួយនោះ លេខនេះអាចយកទៅប្រើប្រាស់សំរាប់សហគ្រាសអាជីវកម្មទាំងអស់របស់អ្នកក្នុងក្រុង Philadelphia ។

**<u>សំគាល់ :</u>** ដើម្បីបើកដំណើរការអាជីវកម្មមួយក្នុងក្រុង Philadelphia អ្នកត្រូវទទួលបាននូវ <u>Business Privilege License (BPL)</u> (អាជ្ញាប័ណ្ណបុព្វសិទ្ធិអាជីវកម្ម) និង <u>Business Tax Number</u> (លេខពន្ធអាជីវកម្ម) ។ ការទទួលបានលេខពន្ធអាជីវកម្មតែមួយមុខ មិនអាចបំពេញ ឬមានអានុភាពលើល័ក្ខខ័ណ្ឌតំរូវចាំបាច់របស់ BPL នោះទេ ។

**ជំហានទី ៣**

<u>ចូរបំពេញបែបបទពាក្យសុំអាជ្ញាប័ណ្ណ (មួយ ឬច្រើន) ។</u>

ពិនិត្យឡើងវិញលើពាក្យសុំ (មួយ ឬច្រើន) និងផ្តល់ព័ត៌មានដែលចាំបាច់ ។ សូមកុំភ្លេចចុះហត្ថលេខាលើពាក្យសុំនោះផង ។

**ជំហានទី ៤**

<u>ដាក់ភ្ជាប់ជាមួយមូលប្បទានប័ត្រ ឬ Money Order (ប័ណ្ណបញ្ជាប្រាក់) សំរាប់ថ្លៃឈ្នួលសមស្រប (ប្រសិនបើអាចធ្វើទៅបាន) ។</u>

ថ្លៃឈ្នួលអាជ្ញាប័ណ្ណមានការប្រែប្រួល ។ ថ្លៃឈ្នួលត្រូវបានគេចុះបញ្ជីនៅលើបែបបទពាក្យសុំនីមួយៗ ។ លោកអ្នកអាចដឹងពីថ្លៃចំណាយលើអាជ្ញាប័ណ្ណជាក់លាក់មួយ ដោយទូរស័ព្ទទៅលេខពិសេសរបស់ License Issuance (ការចេញអាជ្ញាប័ណ្ណ) ។ ។ សូមទូទាត់ជាមូលប្បទានប័ត្រទៅកាន់ទីក្រុង "City of Philadelphia" ។ សូមកុំផ្ញើជាសាច់ប្រាក់អោយសោះ ។ ការបង់ជាសាច់ប្រាក់គឺមិនអាចទទួលយកបានទេ ។

**ជំហានទី ៥**

រៀបចំប្រមូលរាល់ឯកសារចាំបាច់ទាំងអស់ និងប្រគល់កញ្ចប់នោះទៅអោយ License Issuance Unit (អង្គភាពចេញអាជ្ញាប័ណ្ណ) ។

កញ្ចប់ពាក្យសុំដែលលោកអ្នកបំពេញរួចរាល់ គប្បីមាន :

- ✓ ពាក្យសុំអាជ្ញាប័ណ្ណដែលបានបំពេញរួច (មួយ ឬច្រើន) ដោយមានចុះហត្ថលេខា
- ✓ ពាក្យសុំលេខគណនីពន្ធអាជីវកម្ម ដែលបានបំពេញរួច ដោយមានចុះហត្ថលេខា
- ✓ លិខិតឯកភាពចាំបាច់ទាំងអស់
- ✓ មូលប្បទានប័ត្រ ឬ Money Order ( ប័ណ្ណបញ្ជាប្រាក់ ) សំរាប់ថ្លៃអាជ្ញាប័ណ្ណ ដែលចាំបាច់ ( មួយ ឬច្រើន )

សូមផ្ញើកញ្ចប់នេះទៅកាន់អសយដ្ឋាន ដែលមាននៅលើពាក្យសុំអាជ្ញាប័ណ្ណ ឬយកវាទៅតូប License Issuance Customer Service counter (តូបសេវាកម្មអតិថិជននៃការចេញអាជ្ញាប័ណ្ណ) នៅឯ Municipal Services Building – Concourse Level at 1401 JFK Boulevard.

## តើ L & I ធ្វើអ្វីខ្លះ នៅពេលកញ្ចប់ពាក្យសុំទៅដល់ស្ថាប័ននេះ ?

នៅ L & I ទទួលបានកញ្ចប់របស់អ្នក ដំណើរការខាងក្រោមនេះ នឹងកើតឡើង :

1. L & I បញ្ជូនពាក្យសុំលេខគណនីពន្ធអាជីវកម្មរបស់លោកអ្នកទៅក្រសួងចំណូល ដូច្នេះក្រសួងនេះអាចផ្តល់លេខដល់លោកអ្នក ។
2. ក្រសួងចំណូលនឹងបញ្ជូនលេខពន្ធរបស់លោកអ្នកទៅកាន់ L & I ដូច្នេះ License Issuance អាចដំណើរការពិនិត្យលើពាក្យសុំអាជ្ញាប័ណ្ណរបស់លោកអ្នក ។
3. License Issuance (ការចេញអាជ្ញាប័ណ្ណ) នឹងពិនិត្យឡើងវិញលើពាក្យសុំរបស់លោកអ្នកថាតើបានបំពេញចប់សព្វគ្រប់ដែរឬទេ ? ដំណើរការពិនិត្យលើពាកសុំ បញ្ជូនពាក្យសុំដើម្បីទទួលបានការឯកភាព ( ប្រសិនបើគេមិនទាន់ទទួលបានពាក្យសុំនេះនៅឡើយ ) ចេញអាជ្ញាប័ណ្ណអាជីវកម្មរបស់លោកអ្នក និងផ្ញើអាជ្ញាប័ណ្ណនេះអោយលោកអ្នក (ឬប្រគល់អាជ្ញាប័ណ្ណនេះដល់លោកអ្នកនៅឯ counter (តុគិតលុយ) ដោយផ្ទាល់ ក្នុងស្ថានភាពដែលអាចធ្វើទៅបាន ) ។
4. ប្រសិនបើពាក្យសុំរបស់លោកអ្នកបំពេញមិនទាន់អស់ នោះ License Issuance (ការចេញអាជ្ញាប័ណ្ណ) នឹងទាក់ទងមកលោកអ្នកតាមរយៈលេខទូរស័ព្ទ ដែលអ្នកបានសរសេរនៅលើបែបបទពាក្យរបស់លោកអ្នក ឬបញ្ជូនត្រឡប់ពាក្យសុំមកលោកអ្នកវិញតាមប្រៃសណីយ៍ ដើម្បីបំពេញបន្ថែម ។

## តើជាធម្មតាដំណើរការមានរយៈពេលប៉ុន្មាន ?

- រយៈពេលដំណើរការអាស្រ័យលើការបំពេញចប់សព្វគ្រប់លើពាក្យសុំរបស់លោកអ្នក ។ ប្រសិនបើពាក្យសុំត្រូវបានបំពេញចប់ទាំងស្រុង ហើយរាល់ល័ក្ខខ័ណ្ឌជាធរមានទាំងអស់ត្រូវបានបំពេញហើយនោះ ការចេញអាជ្ញាប័ណ្ណរបស់លោក អាចនឹង

ដំណើរការនៅថ្ងៃតែមួយ ។ ទោះជាយ៉ាងណាក៏ដោយ គេអាចពន្យាបន្ថែមរយៈពេលនេះ នៅពេលគេតំរូវអោយមានការឯកភាពបន្ថែមទៀត ។

- ប្រសិនបើមិនមានរាល់ព័ត៌មានចាំបាច់ទាំងអស់នៅពេលដាក់ពាក្យសុំទេនោះ ពាក្យសុំរបស់លោកអ្នកនឹងមិនត្រូវគេទទួលយកនោះឡើយ ។

- ក្នុងករណីជាក់លាក់មួយចំនួន អ្នកដាក់ពាក្យសុំទាំងឡាយនឹងត្រូវបានគេតំរូវអោយបង្ហាញឯកសារសំគាល់អត្តសញ្ញាណមួយចំនួន ដូចជាអត្តសញ្ញាណប័ណ្ណមានរូបថត កាតចុះឈ្មោះបោះឆ្នោត Social Security Carde (កាតសន្តិសុខសង្គម) វិក្កយប័ត្រទឹកភ្លើង ។ល។

<u>**សំគាល់ :**</u> ម៉ោងធ្វើការធម្មតារបស់ License Issuance Unit (អង្គភាពចេញអាជ្ញាប័ណ្ណ)

8:00 AM ដល់ម៉ោង 5:00PM,

ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ

## តើខ្ញុំអាចធ្វើអ្វីបានក្នុងករណី L & I បដិសេធពាក្យសុំរបស់ខ្ញុំ?

ក្នុងករណីការស្នើសុំអាជ្ញាប័ណ្ណរបស់លោកអ្នកត្រូវបានបដិសេធ ឬ អាជ្ញាប័ណ្ណមានស្រាប់របស់លោកអ្នកត្រូវ បានដកហូត លោកអ្នកអាចធ្វើបណ្តឹងឧទ្ធរណ៍លើការសំរេចចិត្តនេះទៅ Board of Licenses and Inspections Review (គណៈកម្មាការត្រួតពិនិត្យអាជ្ញាប័ណ្ណ និងអធិការកិច្ច) ។

ដើម្បីរៀបចំឯកសារបណ្តឹងឧទ្ធរណ៍ សូមទូរស័ព្ទមកគណៈកម្មាការនេះតាមលេខ **686-2427**

## តើខ្ញុំអាចបន្តអាជ្ញាប័ណ្ណថ្មីមួយតាមវិធីណា?

- អាជ្ញាប័ណ្ណភាគច្រើនអាចធ្វើឱ្យមានសុពលភាពថ្មីជារៀងរាល់ឆ្នាំ ហើយថ្ងៃផុតកំណត់ក៏ខុសគ្នាដែរ ។ ជាធម្មតា ការជូនដំណឹងពីការធ្វើឱ្យអាជ្ញាប័ណ្ណមានសុពលភាពថ្មីត្រូវបានផ្ញើចេញដោយស្វ័យប្រវត្តិ ។ លោកអ្នកគ្រាន់តែបង់ថ្លៃលើការជូនដំណឹងជាការស្រេច ។

- ក្នុងករណីមួយចំនួន ការជូនដំណឹងពីការធ្វើឱ្យអាជ្ញាប័ណ្ណមានសុពលភាពថ្មីរបស់លោកអ្នកនឹងប្រាប់លោកអ្នកធ្វើការរៀបចំការស្នើសុំជាថ្មី ។ សូមពិគ្រោះយោបល់អំពីការស្នើសុំអាជ្ញាប័ណ្ណរបស់លោកអ្នក និងសេចក្តីណែនាំដែលមានព័ត៌មានស្តីពីថ្ងៃផុតកំណត់ និងដំណើរការសុំសុពលភាពថ្មីសំរាប់អាជ្ញាប័ណ្ណរបស់លោកអ្នក ។

- ការសុំសុពលភាពថ្មីលើអាជ្ញាប័ណ្ណអាចត្រូវបានធ្វើឡើងដោយបុគ្គលខ្លួនឯងផ្ទាល់ ឬ តាមរយៈការផ្ញើសំបុត្រ។ សូមប្រគល់មូលប្បទានប័ត្រ ឬ money order (ប័ណ្ណបញ្ជាប្រាក់)។ License Issuance (ការចេញអាជ្ញាប័ណ្ណ) នឹងមិនទទួលជាសាច់ប្រាក់នោះឡើយ។

- ការខកខានមិនបានទទួលសុពលភាពថ្មីចាំបាច់ណាមួយ នឹងតំរូវឱ្យលោកអ្នកទទួលខុសត្រូវតាមសកម្មភាពផ្លូវច្បាប់ពីខាងក្រសួងនេះ។.

## តើខ្ញុំគួរដឹងអ្វីផ្សេងទៀតអំពីល័ក្ខខ័ណ្ឌតំរូវទស្តីពីអាជ្ញាប័ណ្ណ?

មានល័ក្ខខ័ណ្ឌតំរូវមួយចំនួនពាក់ព័ន្ធនឹងអាជ្ញាប័ណ្ណដូចជា:

- Business Privilege License (អាជ្ញាប័ណ្ណបុព្វសិទ្ធអាជីវកម្ម)

  អាជ្ញាប័ណ្ណសំរាប់ការធ្វើអាជីវកម្មគឺជាអាជ្ញាប័ណ្ណ ដែលក្រសួង L & I បានចេញច្រើនជាងគេ។ ជនគ្រប់រូបដែលចង់ប្រកបរបរអាជីវកម្មណាមួយនៅទីក្រុង Philadelphia ទោះបីជាជននោះមានទីកន្លែងអាជីវកម្មនៅទីក្រុងនេះឬយ៉ាងណាក៏ដោយ គឺត្រូវតែមានអាជ្ញាប័ណ្ណមួយ។ នេះជាអាជ្ញាប័ណ្ណសំរាប់ពេលវេលាកំណត់ណាមួយ និងអាចត្រូវបានប្រើសំរាប់អាជីវកម្មទាំងអស់ដែលដំណើរការនៅក្នុងទីក្រុងនេះ។

- Multiple Licenses (អាជ្ញាប័ណ្ណពហុប្រភេទ)

  អ្នកប្រកបរបរអាជីវកម្មមួយចំនួនត្រូវការតែអាជ្ញាប័ណ្ណសំរាប់ធ្វើអាជីវកម្មប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ អ្នកប្រកបរបរអាជីវកម្មផ្សេងទៀតត្រូវការអាជ្ញាប័ណ្ណជាច្រើនប្រភេទបន្ថែមលើអាជ្ញាប័ណ្ណសំរាប់ធ្វើអាជីវកម្មនេះ។

  ឧទាហរណ៍ អ្នកលក់ដូរតាមផ្លូវដែលប្រកបរបរលក់ផ្លែឈើ និងបន្លែផ្សេងៗ អាចត្រូវការអាជ្ញាប័ណ្ណបួនប្រភេទដូចជា: អាជ្ញាប័ណ្ណសំរាប់លក់តាមចិញ្ចើមថ្នល់, សំរាប់ការបំរើ និង រៀបចំចំណីអាហារ, សំរាប់ការថ្លឹងដោយជញ្ជីង និងអាជ្ញាប័ណ្ណបុព្វសិទ្ធិអាជីវកម្ម។
  ប្រភេទអាជីវកម្មដែលលោកអ្នកត្រូវការផ្អែកតាមប្រភេទនៃសកម្មភាពអាជីវកម្មដែលលោកអ្នកនឹងធ្វើ។

  បន្ទាប់ពីទូរស័ព្ទមកលេខបំរើសេវាផ្នែកចេញអាជ្ញាប័ណ្ណ នោះតំណាងបំរើសេវាអតិថិជននឹងប្រាប់លោកអ្នកអំពីថាតើលោកអ្នកនឹងត្រូវការអាជ្ញាប័ណ្ណប្រភេទណា ឬអាជ្ញាប័ណ្ណជាច្រើនប្រភេទណាខ្លះ។

## តើមានទីភ្នាក់ងារណាផ្សេងទៀតដែលអាចជួយខ្ញុំក្នុងការចាប់ដំណើរការអាជីវកម្ម?

មានស្ថាប័នមួយចំនួនដែលអាចជួយលោកអ្នកបាន។ ស្ថាប័នទាំងនេះមានដូចខាងក្រោម :

1. **Department of Commerce** (ក្រសួងពាណិជ្ជកម្ម) (ទូរស័ព្ទលេខ: 215-683-2100)
   One Parkway / 1515 Arch Street – 12th Floor
   Philadelphia, PA 19102

   Department of Commerce (ក្រសួងពាណិជ្ជកម្ម) នេះ ជាផ្នែកដ៏សំខាន់នៃទីក្រុងនេះសំរាប់អភិវឌ្ឍ សេដ្ឋកិច្ច។ ក្រសួងនេះជាអ្នកអនុវត្តគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច ហើយមានគោលដៅចំបងមួយគឺគាំទ្រលើសកម្មភាពណាដែលជំរុញឱ្យមានឱកាសសេដ្ឋកិច្ចសំរាប់ប្រជាជននៅទីក្រុង។ តាមរយៈការប្រើប្រាស់មូលនិធិតាមមូលដ្ឋាន រដ្ឋ និងសហព័ន្ធ ក្រសួង ពាណិជ្ជកម្មនេះអាចជួយទ្រទ្រង់ដល់ការស្តារ និងស្ថាបនាពាណិជ្ជកម្ម និង ឧស្សាហកម្ម និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង អាជីវកម្ម។

2. **City of Philadelphia - Mayor's Business Action Team**
   (ក្រុមសកម្មភាពអាជីវកម្មរបស់ចៅហ្វាយក្រុង) (ទូរស័ព្ទលេខ: 215-683-2100)
   One Parkway / 1515 Arch Street – 12th Floor
   Philadelphia, PA 19102

   The Mayor's Business Action Team (MBAT) (ក្រុមសកម្មភាពអាជីវកម្មរបស់ចៅហ្វាយក្រុង) ជាផ្នែកមួយនៃក្រសួងពាណិជ្ជកម្មរបស់ទីក្រុង ដែលផ្តល់ប្រភពជំនួយអាជីវកម្មដែលអាចទុកចិត្តបាន និងយ៉ាងច្រើន ដល់អាជីវកម្មនៅ Philadelphia ។ MBAT ជាចំណុចទំនាក់ទំនងដ៏សំខាន់រវាង Department of Commerce (ក្រសួងពាណិជ្ជកម្ម) និងសហគមន៍អាជីវកម្ម។ MBAT business account executives (ក្រុមប្រតិបត្តិលើគណនីអាជីវកម្មរបស់ MBAT) ជាក្រុមដែលមានចំណេះដឹងយ៉ាងទូលំទូលាយលើព័ត៌មានទាក់ទងនឹងអាជីវកម្ម ដូចជាល័ក្ខខ័ណ្ឌតំរូវនៃការចាប់ផ្តើមអាជីវកម្ម ការផ្តល់អាជ្ញាប័ណ្ណ និងការចេញលិខិតអនុញ្ញាតផ្សេងៗ។ MBAT ក៏ជួយសំរុះសំរួលរវាងក្រសួងទីក្រុង និងស្ថាប័នផ្សេងៗដើម្បីដោះស្រាយបញ្ហាអាជីវកម្ម និងធានាឱ្យបាននូវសេវាកម្មពេញលេញក្នុងទីក្រុងផ្សេងៗជាច្រើន។

3. **Philadelphia Commercial Development Corporation** (**កិច្ចសហប្រតិបត្តិការអភិវឌ្ឍពាណិជ្ជកម្មរបស់ទីក្រុង Philadelphia**) (ទូរស័ព្ទលេខ: 215-238-7676)
   714 Market Street – Suite 433
   Philadelphia, PA 19106

   The Philadelphia Commercial Development Corporation (PCDC) (កិច្ចសហប្រតិបត្តិការអភិវឌ្ឍពាណិជ្ជកម្មរបស់ទីក្រុង Philadelphia) ជាស្ថាប័នដ៏សំខាន់មួយរបស់ទីក្រុងក្នុងការជួយដល់អាជីវកម្មខ្នាតតូចរបស់អ្នកជិតខាងនៃទីក្រុងនេះទាំងអស់។ PCDC មានបេសកកម្មធ្វើឱ្យភាពជាអ្នកជិតខាងកាន់តែមានល្អប្រសើរ និងជួយអាជីវកម្មខ្នាតតូច។ សេវាកម្មហិរញ្ញវត្ថុរបស់ PCDC មានការផ្តល់កម្ចីដល់អាជីវកម្មខ្នាតតូចដូចជាមូលនិធិកម្ចីនេះដើម្បីធ្វើជាមូលនិធិកម្ចីសំរាប់អភិវឌ្ឍអាជីវកម្មខ្នាតតូច កម្មវិធីម៉ៅការសាងសង់ទីលំនៅ មូលនិធិកម្ចី Comcast

និងមូលនិធិកម្ចីមីក្រូសំរាប់អាជីវកម្មខ្នាតតូច។ PCDC ក៏ជាអ្នកគ្រប់គ្រងលើកម្មវិធីធ្វើឱ្យប្រសើរឡើងនូវពាណិជ្ជកម្ម ជាមួយអ្នកជិតខាងរបស់ទីក្រុង។

4. **Women's Business Development Center** (មជ្ឈមណ្ឌលអភិវឌ្ឍអាជីវកម្មស្ត្រី) (ទូរស័ព្ទលេខ: 215-790-9232)
1315 Walnut Street – 11th Floor
Philadelphia, PA 19107

The Women's Business Development Center (WBDC) (មជ្ឈមណ្ឌលអភិវឌ្ឍអាជីវកម្មស្ត្រី) ជាអង្គការមិន សំដៅប្រាក់ចំណេញមួយដែលប្តេជ្ញាចិត្តជួយដល់ស្ត្រីក្នុងតំបន់ Philadelphiaធំជាងដើម្បីសំរេចបានភាព គ្រប់គ្រាន់ផ្នែកសេដ្ឋកិច្ចដោយខ្លួនឯង។ WBDC ផ្តល់ផលិតផល និងសេវាកម្មដែលជំរុញការផ្តល់អំណាចសេដ្ឋកិច្ច ដល់ស្ត្រី បង្កើនអាជីវកម្មដែលគ្រប់គ្រងដោយស្ត្រី និងពង្រឹងឥទ្ធិពលរបស់ស្ត្រីលើសេដ្ឋកិច្ចតំបន់។

4. **Minority Business Enterprise Council** (ក្រុមប្រឹក្សាស្តីពីសហគ្រាសអាជីវកម្មសំរាប់ជនជាតិភាគតិច) (ទូរស័ព្ទលេខ: 215-686-6370)
Municipal Services Building / 1401 John F. Kennedy Boulevard – Suite 330
Philadelphia, PA 19102

The Minority Business Enterprise Council (MBEC) (ក្រុមប្រឹក្សាស្តីពីសហគ្រាសអាជីវកម្មសំរាប់ ជនជាតិភាគតិច) ត្រូវបានបង្កើតឡើងនៅឆ្នាំ 1982 ដើម្បីធានាឱ្យមានសហគ្រាសគ្រប់គ្រងដោយជនជាតិភាគតិច និងផ្តល់លទ្ធភាពទទួល្យ និងឱកាសស្មើគ្នាក្នុងការប្រកួតប្រជែង និងធានាសុវត្ថិភាពដល់កិច្ចសន្យាក្នុងទីក្រុងហ្វីឡាដិលហ្វៀ។ MBEC មានតួនាទីមួយចំនួនដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចតាមរយៈកម្មវិធីផ្តល់ការបញ្ជាក់របស់ខ្លួន កាត្រួតពិនិត្យមើលកិច្ចសន្យា និងសកម្មភាពតាមដាន និង ការប្រាស្រ័យទាក់ទងជាបន្តបន្ទាប់ជាមួយក្រសួង ទីក្រុងផ្សេងៗទៀត (quasi-public agencies) ទីភ្នាក់ងារពាក់កណ្តាលសាធារណៈ និងទីផ្សារក្នុងស្រុក

6. **State of Pennsylvania – Small Business Action Center** (មជ្ឈមណ្ឌល សកម្មភាពអាជីវកម្មខ្នាតតូច)
P.O. Box 8100
Harrisburg, PA 17105

សូមសរសេរលិខិតស្នើសុំព័ត៌មាន។

7. **Small Business Development Centers (SBDCs)** (មជ្ឈមណ្ឌលអភិវឌ្ឍអាជីវកម្មខ្នាតតូច)

លោកអ្នកអាចរកឱ្យមជ្ឈមណ្ឌលដែលរៀបចំឡើងនៅទូទាំងរដ្ឋទាំងនេះជួយលោកអ្នកបាន ។ មជ្ឈមណ្ឌលមួយចំនួនមានទីតាំងនៅតាមមហាវិទ្យាល័យ និងសាកលវិទ្យាល័យមួយចំនួននៅទីក្រុង Philadelphia ។ សំរាប់ព័ត៌មានផ្សេងៗ សូមទូរស័ព្ទមក ៖

- University of Pennsylvania (សាកលវិទ្យាល័យផេនស៊ីលវ៉ានី) – The Wharton School (សាលារៀនវ៉ាត់តន់) (ទូរស័ព្ទលេខ: 215-898-1219)
- Temple University (សាកលវិទ្យាល័យថែមផល) (ទូរស័ព្ទលេខ: 215-204-7282)
- LaSalle University (សាកលវិទ្យាល័យឡាសែល) (ទូរស័ព្ទលេខ: 215-951-1416)
- Drexel University (សាកលវិទ្យាល័យឌ្រេចស៊ែរុល) (ទូរស័ព្ទលេខ: 215-895-0302)

8. **Philadelphia Chamber of Commerce** (សភាពាណិជ្ជកម្មហ្វីឡាដិលហ្វៀ) (ទូរស័ព្ទលេខ: 215-545-1234)
200 South Broad Street – Suite 700
Philadelphia, PA 19102

Greater Philadelphia Chamber of Commerce (សភាពាណិជ្ជកម្មហ្វីឡាដិលហ្វៀធំជាងមុន) គឺប្តេជ្ញា ជួយ និងជំរុញកំណើនបន្តបន្ទាប់របស់ក្រុមហ៊ុនជាសាមាជិកនីមួយៗក្នុងចំណោមក្រុមហ៊ុនជាសាមាជិកជិត 6,000 របស់ខ្លួន និងសហគមន៍អាជីវកម្មទាំងមូល ។
គោលបំណងចំបងៗរបស់សភាពាណិជ្ជកម្មនេះគឺឱ្យមានឥទ្ធិពលដល់ការតាក់តែងច្បាប់ក្នុងរដ្ឋាភិបាលឱ្យសមស្របសំរាប់អាជីវកម្ម ចូលរួមនៅក្នុងគំនិតផ្តួចផ្តើមក្នុងគោលបំណងលើកកំពស់ការអប់រំ និងសហគមន៍ ផ្តល់ជូននូវកម្មវិធីអភិវឌ្ឍដែលមានវិជ្ជាជីវៈ និងផ្តល់ឱ្យសមាជិករបស់ខ្លួននូវវិធីសាស្ត្រគ្រប់គ្រងអាជីវកម្មដែលប្រកបដោយប្រសិទ្ធភាពលើថ្លៃចំណាយរបស់ខ្លួន ។

---

### ជួសមុខឱ្យក្រសួងអាជ្ញាប័ណ្ណ និងអធិការកិច្ច

### សូមថ្លែងអំណរគុណដល់លោកអ្នកដែលបានជ្រើសរើសប្រកបរបរអាជីវកម្មនៅក្នុង Philadelphia ។

### <u>យើងរីករាយនឹងបំរើលោកអ្នកជានិច្ច ។</u>